**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......១៤៤/១១..........ក.ប/ប្រ.ក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គ.ប.ស.ស.

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

-បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តនៃច្បាប់ស្តីពីការងារ

-យោងលិខិតលេខ ០៨៧ មស.នក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១. –**

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ប.ស.ស.** ដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើត

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ២.-**

បង្កើតលេខាធិការដ្ឋាននៃ **គ.ប.ស.ស.**ដែលមានរចនាសម្ព័ន្ធស្មើនឹងការិយាល័យថ្នាក់កណ្តាល ។ លេខាធិការដ្ឋាននៃ **គ.ប.ស.ស.** ដឹកនាំដោយប្រធាន០១រូប អនុប្រធានចំនួន០២រូប និងមន្ត្រីមួយចំនួនតាមការចាំបាច់ជាជំនួយការ។

ប្រធាន អនុប្រធាន និងមន្ត្រី នៃលេខាធិការដ្ឋាន **គ.ប.ស.ស.** គឺជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៣.-**

លេខាធិការដ្ឋាន **គ.ប.ស.ស.**មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងឯកសាររដ្ឋបាលផ្ទៃក្នុង និងចរាចរលិខិតចេញ-ចូល របស់ **គ.ប.ស.ស.**

-រៀបចំ ប្រមូល ចងក្រងនិងរក្សាទុកនូវឯកសារពាក់ព័ន្ធនឹងការងាររបស់**គ.ប.ស.ស.**

-សម្របសម្រួលនិងអនុវត្តកិច្ចការរដ្ឋបាលទូទៅរបស់ **គ.ប.ស.ស.**

-ធ្វើកំណត់ហេតុអង្គប្រជុំរបស់ **គ.ប.ស.ស.**

-ធ្វើរបាយការណ៍សកម្មភាពការងាររបស់**គ.ប.ស.ស.**ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ

-គ្រប់គ្រងនិងរៀបចំគម្រោងថវិការបស់**គ.ប.ស.ស.**

-ទទួលអនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាន **គ.ប.ស.ស.**។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកការងារ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ប្រធានក្រុមប្រឹក្សាបច្ចេករបបសន្តិសុខសង្គម នាយកបេឡាជាតិរបបសន្តិសុខសង្គម ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**វង សូត**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ខុទ្ទការល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទការល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី

-ក្រុមប្រឹក្សាភិបាល នៃប.ស.ស

"ដើម្បីជូនជ្រាប"

-ប្រការ៥ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ